**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២០៧......សហវ.ប្រក.

# ប្រកាស
## ស្តីពីការដកហូតអាជ្ញាប័ណ្ណ
## អាជីវកម្មភ្នាល់កីឡារបស់ក្រុមហ៊ុន Betting Zone Limited.

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ៧០ សជណ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអាជ្ញាប័ណ្ណលេខ ០៣២ សហវ.ឧហ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨ ផ្តល់ជូនលោកនាយកក្រុមហ៊ុន Betting Zone Limited
- បានឃើញសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល
- បានឃើញសេចក្តីជូនដំណឹងលេខ ០០១ សហវ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១ :** ដកហូតអាជ្ញាប័ណ្ណលេខ ០៣២ សហវ.ឧហ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨ របស់ក្រុមហ៊ុន Betting Zone Limited តាមស្មារតីនៃសេចក្តីជូនដំណឹងលេខ ០០១ សហវ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**ប្រការ ២ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីក្រុមហ៊ុន ត្រូវទទួលអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៣ :** ប្រកាសនេះ មានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- គ្រប់សាលាខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធ

  " ដើម្បីជូនជ្រាប "
- ឯកសារ-កាលប្បវត្តិ